បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

**ឆ្នាំទី ៧ លេខ ៨ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧**

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៤-០២-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣៤ តែងតាំងឯកឧត្តម លី ចាណា ជាអគ្គនាយកកិច្ចការរដ្ឋបាល ឯកឧត្តម ប៊ុន ហ៊ាន ជាអគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម ២៩៤
២៥-០២-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣៥ តែងតាំងឯកឧត្តម ចាន់ ណារ៉េត ជាសាកលវិទ្យាធិការ សាលក វិទ្យាល័យភូមិន្ទកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៩៥

## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៤-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៦
២៦-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧
២៦-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧
២៦-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៨
២៦-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៩
២៦-០២-១៩៩៩ -អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣០០

## III- ការិយាល័យក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

#### ប្រកាស

២៥-០២-១៩៩ -ប្រកាសលេខ ៥៤១ ពណ.បអព ស្តីពីលទ្ធផល នៃការដេញថ្លៃកូតា នាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ៣០១

### ២.ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

#### ប្រកាស

២៤-០២-១៩៩ -ប្រកាសលេខ ២៦៩ ឧក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីស៊ីន ខេមបូឌៀ នីតធីង កូ អិលធីឌី តំណាងដោយលោកស្រី WANG FANG សញ្ជាតិចិន បង្កើតរោងចក្រ ចាក់សំលៀកបំពាក់នាំចេញ ៣០៧

## ៣- នីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

### ប្រកាស

២៦-០២-១៩៩ -ប្រកាសលេខ ៣០ ប្រក.វវស.ប ស្តីពីការតែងតាំងមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង ៣០៨

## ៤.នីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស

២៥-០២-១៩៩ -សេចក្តីប្រកាសលេខ ១៥៧ ប្រក.កសក.ចត ស្តីពីការបង្កើតការិយាល័យវាយតំលៃហេតុប៉ះពាល់បរិស្ថាន ៣០៩

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំង ៖

- ឯកឧត្តម លី ថាណា ជាអគ្គនាយកកិច្ចការរដ្ឋបាល
- ឯកឧត្តម ម៉ិន ហ៊ាន ជាអគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និងឧតុនិយម

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម ចាន់ ណារ៉េត ជាសកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តឲ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II- រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ៨៤ អនក្រ.តត

### ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន និងបុគ្គល ដែលបានធ្វើអំណោយជាអាគារសិក្សា ០២ខ្នង និងសំភារៈផ្សេងៗទៀតជូនសាលាបឋមសិក្សាបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានតំលៃសរុប ចំនួន ៨០.០០០ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១- THE INTERNATIONAL ASSOCIATION OF LIONS CLUB 333-C. DISTRICT A-C-T FUND

២- លោក ZENJIRO MATSUMARU ប្រធាន CHIBA PREF. LIONS CLUB

៣- លោកប្រធាន JOSEI HAY'ASHI

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៤៥ អនក្រ.តត
## ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ខេត្តកំពង់ស្ពឺ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក ILKO BAN ប្រធានអង្គការ ZAO ប្រចាំស្រុក បសេដ្ឋ ដែលបានបរិច្ចាគថវិកា ចំនួន ២៥.០០០ដុល្លារអាមេរិក សំរាប់កសាងអាគារសិក្សាមួយខ្នង រួមទាំងសម្ភារៈគ្រប់គ្រាន់ជូនសាលាបឋមសិក្សាទួលស្គរ ក្នុងឃុំព្រះខែ ស្រុក បសេដ្ឋ ខេត្ត កំពង់ស្ពឺ ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត កំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ៤៦ អនក្រ.តត
## ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលស្រុក ជុំគីរី ខេត្ត កំពត

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលបានជួយកសាងអាគារសិក្សាមួយខ្នងរួមនឹងសង្ហារឹមសិក្សាគ្រប់គ្រាន់ ជូនសាលាបឋមសិក្សា អង្គជុំ ស្ថិតក្នុងឃុំ ស្រែក្នុង ចំណាយអស់ទឹកប្រាក់ ចំនួន ២០.០០០ដុល្លារអាមេរិក ព្រមទាំងជួយឧបត្ថម្ភប្រាក់ ២.០០០ដុល្លារអាមេរិក ក្នុងមួយឆ្នាំសំរាប់ទ្រទ្រង់សាលានេះ រយៈពេល ០៥ឆ្នាំ ដូចមាននាមខាងក្រោម ៖

១- លោក វរសេនីយឯក ឃុន ទុង

២- លោក អាន យុខស៊ីញ ប្រធានក្រុមហ៊ុនប្រេងឥន្ធនៈ

មាត្រា ២ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៤៧ អនក្រ.តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលក្រុងព្រះសីហនុ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន SOKIMEIX ដែលបានជួយកសាងផ្លូវត្រង់ចំណុចបំបែកស្ថានីយ៍រថភ្លើងក្រុងព្រះសីហនុ ចំណាយអស់ទឹកប្រាក់ ចំនួន ២១.២៥៦ ដុល្លារអាមេរិក ។

មាត្រា ២ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤៨ អនក្រ.តត
## ស្ដីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ HEKS ដែលបានធ្វើ អំណោយជាអាគារសិក្សាមួយខ្នង បំពាក់ដោយសំភារៈ តុ កៅអី គ្រប់គ្រាន់ជូនសាលាបឋមសិក្សាតាកឹម ស្ថិតក្នុងឃុំតាអែម ស្រុកត្រាំកក់ ខេត្តតាកែវ មានតំលៃជាប្រាក់ ចំនួន ១៥.៩០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត តាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ៤៩ អនក្រ.តត

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគធនធានសំរាប់ជួយកសាងសមិទ្ធផលផ្សេងៗ ប្រគេនព្រះសង្ឃក្នុងវត្តស្រះឈូក និងវត្តសំបួរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់ថវិកា ចំនួន ១០.[illegible]៥០ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោក ព្រាប ឌុយណេ
២- លោកស្រី សុខ យឿក

មាត្រា ២ .- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

***

# III- ការងារបណ្តាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ៥៨១ ពណ.បអព

### ស្តីពីលទ្ធផលនៃការដេញថ្លៃកូតានាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក

*****

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៦/ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌ ធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩

- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ៥៦៩ MoC/M99 ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការដាក់ឲ្យដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក
- យោងតាមការចាំបាច់នៃការងារ

**សំរេច**

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិក ដែលបានប្រព្រឹត្តិទៅ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុង ANNEX A ។

**ប្រការ ២ :** កូតាក្នុងប្រភេទ ៣៣១/៦៣១- ស្រោមដៃធ្វើពីកប្បាស និងសរសៃសិប្បនិម្មិត ចំនួន ១១២,០០០ឡូត៍គូ ត្រូវទុកដាក់ដេញថ្លៃសារជាថ្មី អាស្រ័យដោយគ្មានអ្នកចូលរួមដេញថ្លៃ។

**ប្រការ ៣ :** ក្រុមហ៊ុនទាំងឡាយ ដែលមានចែងក្នុងប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% ឲ្យបានមុនថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ។ ការអាក់ខានបង់នឹងអាចនាំឲ្យដល់ការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដេញបានយកទៅទុកដេញថ្លៃនៅលើកក្រោយវិញ ។

**ប្រការ ៤:** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និងសមាជិកគណៈកម្មការគ្រប់គ្រងកូតា សំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ ។ ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខានិងត្រា
**ចម ប្រសិទ្ធ**

★★★

EXPORTED QUOTA MANAGEMENT COMMITTEE (E.Q.M.C)

ANNEXA
MINISTRY OF COMMERCE
TENDER for QUOTA ON 25 Fed.1999

**RESULT**

| ID | COMPANY NAME | CAT : 334/634 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 8,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | SPORTEX | 1,600 | 21 | 33,600 | 3 | 30,240 |

| | | | | | | |
|---|---|---|---|---|---|---|
| 2 | W&D (CAMBODIA) CO., LTD | 1,600 | 12 | 19,200 | 1,920 | 17,280 |
| 3 | KUN MAO HSING | 800 | 8 | 6,400 | 640 | 5,760 |
| 4 | SUPREME | 1,600 | 8 | 12,800 | 1,280 | 11,520 |
| 5 | KUN MAO HSING | 800 | 7 | 5,600 | 560 | 5,040 |
| 6 | JACQSINTEX INDUSTRIES CAMBODIA CO., LTD | 1,000 | 6 | 6,000 | 600 | 5,400 |
| 7 | DUSON CAMBODIA | 600 | 5 | 3,000 | 300 | 2,700 |
| | TOTAL | 8,000 | | 86,600 | 8,660 | 77,940 |

| ID | COMPANY NAME | CAT : 335/635 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 2,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | KUN MAO HSING | 200 | 8 | 1,600 | 160 | 1,440 |
| 2 | SUPREME | 400 | 8 | 3,200 | 320 | 2,880 |
| 3 | KUN MAO HSING | 200 | 7 | 1,400 | 140 | 1,260 |
| 4 | CAMBOTEX H.K | 400 | 6 | 2,400 | 240 | 2,160 |
| 5 | W&D (CAMBODIA) CO., LTD | 400 | 6 | 2,400 | 240 | 2,160 |
| 6 | BROADLAND CAMBODIA | 200 | 5 | 1,000 | 100 | 900 |
| 7 | DUSON CAMBODIA | 200 | 5 | 1,000 | 100 | 900 |
| | TOTAL | 2,000 | | 13,000 | 1,300 | 11,700 |

| ID | COMPANY NAME | CAT : 338/339 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 100,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | WINNER KNITTING FACTORY LTD | 10,000 | 14 | 140,000 | 14,000 | 126,000 |
| 2 | EMPEROR | 20,000 | 12 | 240,000 | 24,000 | 216,000 |
| 3 | RAO YUAN GARMENT | 20,000 | 12 | 240,000 | 24,000 | 216,000 |
| 4 | SAM HAN CAMBODIA | 10,000 | 12 | 120,000 | 12,000 | 108,000 |
| 5 | THAI PORE | 20,000 | 12 | 240,000 | 24,000 | 216,000 |
| 6 | GREAT LANCELOT | 11,666 | 11 | 128,326 | 12,833 | 115,493 |
| 7 | TERRATEX KNITTING & GARMENT | 8,334 | 11 | 91,674 | 9,167 | 82,507 |
| | TOTAL | 100,000 | | 1,200,000 | 120,000 | 1,080,000 |

| ID | COMPANY NAME | CAT : 340/640 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 12,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | W & D (CAMBODIA) CO., LTD | 800 | 9 | 7,200 | 720 | 6,480 |
| 2 | GRACE SUN CAMBODIA GARMENT LTD | 2,400 | 6 | 14,400 | 1,440 | 12,960 |
| 3 | BEST HONOUR INTERNATIONAL GARMENT | 2,400 | 5 | 12,000 | 1,200 | 10,800 |
| 4 | W & D (CAMBODIA) CO., LTD | 1,600 | 5 | 8,000 | 800 | 7,200 |
| 5 | GOLD FAME | 2,000 | 4 | 8,000 | 800 | 7,200 |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | GOLDEN JET | 1,200 | 4 | 4,800 | 480 | 4,320 |
| 7 | CITY NEW GARMENT FACTORY | 113 | 3 | 339 | 34 | 305 |
| 8 | ETERNAL | 268 | 3 | 804 | 80 | 724 |
| 9 | GOLDEN JET | 134 | 3 | 402 | 40 | 362 |
| 10 | GOLD-KAMVIMEX GARMENT FACTORY LTD | 113 | 3 | 339 | 34 | 305 |
| 11 | HORUS INDUSTRIAL | 268 | 3 | 804 | 80 | 724 |
| 12 | MSI | 268 | 3 | 804 | 80 | 724 |
| 13 | SOUTH BAY ENTERISE CO., LTD | 168 | 3 | 504 | 50 | 454 |
| 14 | WING TAI APPAREL (CAMBODIA) LTD | 268 | 3 | 804 | 80 | 724 |
| | TOTAL | 12,000 | | 59,200 | 5,920 | 53,282 |

| ID | COMPANY NAME | CAT : 345 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 8,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | GOLD FAME | 1,600 | 20 | 32,000 | 3,200 | 28,800 |
| 2 | BU MIN CAMBODIA | 1,163 | 14 | 16,282 | 1,628 | 14,654 |
| 3 | DA JOO CAMBODIA LTD | 1,163 | 14 | 16,282 | 1,628 | 14,654 |
| 4 | EVERGREEN GARMENT CO., LTD | 1,163 | 14 | 16,282 | 1,628 | 14,654 |
| 5 | S.H INTERNATIONAL CO., LTD | 1,163 | 14 | 16,282 | 1,628 | 14,654 |
| 6 | SAM HAN CAMBODIA | 1,163 | 14 | 16,282 | 1,628 | 14,654 |
| 7 | WINNER KNITTING FACTORY LTD | 585 | 14 | 8,190 | 819 | 7,371 |
| | TOTAL | 8,000 | | 121,600 | 12,160 | 109,440 |

| ID | COMPANY NAME | CAT : 347/348/647/648 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 229,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | SPORTEX | 5,000 | 18 | 90,000 | 9,000 | 81,000 |
| 2 | SU TONG FANG | 5,000 | 16 | 80,000 | 8,000 | 72,000 |
| 3 | TAI YANG | 45,800 | 15 | 687,000 | 68,700 | 618,300 |
| 4 | ZHENG YONG GMT | 45,800 | 15 | 687,000 | 68,700 | 618,300 |
| 5 | INSM GARMENT CO., LTD | 10,000 | 14 | 140,000 | 14,000 | 126,000 |
| 6 | RAO YUAN GARMENT | 25,000 | 12 | 300,000 | 30,000 | 270,000 |
| 7 | SPORTEX | 10,000 | 12 | 120,000 | 12,000 | 108,000 |
| 8 | W & D (CAMBODIA) CO., LTD | 1,500 | 12 | 18,000 | 1,800 | 16,200 |
| 9 | INSM GARMENT CO., LTD | 10,000 | 11 | 110,000 | 11,000 | 99,000 |
| 10 | SU TONG FANG | 35,000 | 11 | 385,000 | 38,500 | 346,500 |
| 11 | FAME CAMBODIA | 9,174 | 10 | 91,740 | 9,174 | 82,566 |
| 12 | RAO YUAN GARMENT | 12,721 | 10 | 127,210 | 12,721 | 114,489 |
| 13 | WING TAI APPAREL (CAMBODIA) LTD | 14,005 | 10 | 140,050 | 14,005 | 126,045 |
| | TOTAL | 229,000 | | 2,976,000 | 297,600 | 2,678,400 |

| ID | COMPANY NAME | CAT : 352/652 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 56,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | SUNTEX PTE LTD | 5,000 | 5 | 25,000 | 2,500 | 22,500 |
| 2 | SUNTEX PTE LTD | 5,000 | 3 | 15,000 | 1,500 | 13,500 |
| 3 | SUPREME | 1,000 | 3 | 3,000 | 300 | 2,700 |
| 4 | SUPREME | 2,000 | 2 | 4,000 | 400 | 3,600 |
| 5 | UNITED ARTS | 11,000 | 2 | 22,000 | 2,200 | 19,800 |
| 6 | CAMBODIA GARMENT LTD | 8,000 | 1 | 8,000 | 800 | 7,200 |
| 7 | CITY NEW GARMENT FACTORY | 8,000 | 1 | 8,000 | 800 | 7,200 |
| 8 | HORUS INDUSTRIAL | 8,000 | 1 | 8,000 | 800 | 7,200 |
| 9 | M & A CAMBODIA GARMENTS LTD | 8,000 | 1 | 8,000 | 800 | 7,200 |
| | TOTAL | 56,000 | | 101,000 | 10,100 | 90,900 |

| ID | COMPANY NAME | CAT : 438 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 3,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | GOLD FAME | 600 | 20 | 12,000 | 1,200 | 10,800 |
| 2 | JOIN RIGHT | 600 | 10 | 6,000 | 600 | 5,400 |
| 3 | MIGHTI SPECTRA KNITTING | 600 | 10 | 6,000 | 600 | 5,400 |
| 4 | SAM HAN CAMBODIA | 600 | 10 | 6,000 | 600 | 5,400 |
| 5 | BU MIN CAMBODIA | 100 | 8 | 800 | 80 | 720 |
| 6 | DA JOO CAMBODIA LTD | 100 | 8 | 800 | 80 | 720 |
| 7 | EVERGREEN GARMENT CO., LTD | 100 | 8 | 800 | 80 | 720 |
| 8 | LEIFENG | 100 | 8 | 800 | 80 | 720 |
| 9 | S.H INTERNATIONAL CO., LTD | 100 | 8 | 800 | 80 | 720 |
| 10 | TERRATEX KNITTING & GARMENT | 100 | 8 | 800 | 80 | 720 |
| | TOTAL | 3,000 | | 34,800 | 3,480 | 31,320 |

| ID | COMPANY NAME | CAT : 445/446 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 9,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | FAME CAMBODIA | 1,800 | 19 | 34,200 | 3,420 | 30,780 |
| 2 | BU MIN CAMBODIA | 1,200 | 15 | 18,000 | 1,800 | 16,200 |
| 3 | DA JOO CAMBODIA LTD | 1,200 | 15 | 18,000 | 1,800 | 16,200 |
| 4 | EVENGREEN GARMENT CO., LTD | 1,200 | 15 | 18,000 | 1,800 | 16,200 |
| 5 | GOLD FAME | 1,200 | 15 | 18,000 | 1,800 | 16,200 |
| 6 | S.H INTERNATIONAL CO., LTD | 1,200 | 15 | 18,000 | 1,800 | 16,200 |
| 7 | SAM HAN CAMBODIA | 1,200 | 15 | 18,000 | 1,800 | 16,200 |

| | | | | | | |
|---|---|---|---|---|---|---|
| | TOTAL | 9,000 | | 142,200 | 14,220 | 127,980 |

| ID | COMPANY NAME | CAT : 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 51,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | WINNER KNITTING FACTORY LTD | 5,100 | 14 | 71,400 | 7,140 | 64,260 |
| 2 | LEIFENG | 10,200 | 10 | 102,000 | 10,200 | 91,800 |
| 3 | WINNER KNITTING FACTORY LTD | 5,100 | 10 | 51,000 | 5,100 | 45,900 |
| 4 | YUNG WAH INDUSTRIAL (CAMBODIA) CO., LTD | 5,000 | 9 | 45,000 | 4,500 | 40,500 |
| 5 | GLADPEER | 5,000 | 8 | 40,000 | 4,000 | 36,000 |
| 6 | FAME CAMBODIA | 5,000 | 7 | 35,000 | 3,500 | 31,500 |
| 7 | TAI YANG | 10,200 | 7 | 71,400 | 7,140 | 64,260 |
| 8 | GLADPEER | 380 | 6 | 2,280 | 228 | 2,052 |
| 9 | GOLD FAME | 730 | 6 | 4,380 | 438 | 3,942 |
| 10 | GRACE SUN CAMBODIA GARMENT LTD | 366 | 6 | 2,196 | 220 | 1,976 |
| 11 | GREAT LANCELOT | 350 | 6 | 2,100 | 210 | 1,890 |
| 12 | HONEY WEAR GARMENT | 730 | 6 | 4,380 | 438 | 3,942 |
| 13 | JACQSINTEX INDUSTRIES CAMBODIA CO., LTD | 110 | 6 | 660 | 66 | 594 |
| 14 | SAM HAN CAMBODIA | 745 | 6 | 4,470 | 447 | 4,023 |
| 15 | SHARP CASUAL CO., LTD | 745 | 6 | 4,470 | 447 | 40,123 |
| 16 | SIN LAN HO | 512 | 6 | 3,072 | 307 | 2,765 |
| 17 | TERRATEX KNITTING & GARMENT | 366 | 6 | 2,196 | 220 | 1,976 |
| 18 | YUNG WAH INDUSTRIAL (CAMBODIA) CO., LTD | 366 | 6 | 2,196 | 220 | 1,976 |
| | TOTAL | 51,000 | | 448,200 | 44,820 | 403,380 |

| ID | COMPANY NAME | CAT : 645/646 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER : 14,000 | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL 90% |
| 1 | WINNER KNITTING FACTORY LTD | 1,400 | 12 | 16,800 | 1,680 | 15,120 |
| 2 | WINNER KNITTING FACTORY LTD | 1,400 | 8 | 11,200 | 1,120 | 10,080 |
| 3 | CHEUNG HING | 170 | 6 | 1,020 | 102 | 918 |
| 4 | C-ONE CAMBODIA GARMENT | 2,800 | 6 | 16,800 | 1,680 | 15,120 |
| 5 | GOLD FAME | 2,800 | 6 | 16,800 | 1,680 | 15,120 |
| 6 | SAM HAN CAMBODIA | 2,800 | 6 | 16,800 | 1,680 | 15,120 |
| 7 | SUPER FINE | 2,630 | 4 | 10,520 | 1,052 | 9,468 |
| | TOTAL | 14,000 | | 89,940 | 8,994 | 80,946 |

★★★

# ២.និស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

**ប្រកាសលេខ ២៦៩ ឧក.ប្រក**

* * *

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ លិខិតលេខ ២៣៦៦.៩៨ គ.វ.ក ចុះថ្ងៃទី ១៦-១១-១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ លិខិតលេខ ០៩០ ឈ.អ ចុះថ្ងៃទី ១០-៩-១៩៩៨ របស់សាលាខេត្តកណ្តាល ស្តីពីការអនុញ្ញាតឲ្យសាងសង់អគាររោងចក្រកាត់ដេរសំលៀកបំពាក់
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីស៊ីន ខេមបូឌា នីតធីង កូ អិលធីឌី ចុះថ្ងៃទី ២២-០២-១៩៩៩ •

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីស៊ីន ខេមបូឌា នីតធីង កូ អិលធីឌី (ECENT CAMBODIA KNITTING CO., LTD) តំណាងដោយលោកស្រី WANG FANG សញ្ជាតិ ចិន ភេទស្រីអាយុ ៣៤ឆ្នាំ អាស័យដ្ឋាន #69 Kunming Road, Weihai Shandong, P.R.of CHINA កាន់លិខិតឆ្លងដែនលេខ P2684685 ចុះថ្ងៃទី ២០-៥-១៩៩៦ បង្កើត "រោងចក្រចាក់សំលៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា "រោងចក្រចាក់សំលៀកបំពាក់ អ៊ីស៊ីន ខេមបូឌា នីតធីង" មានទីតាំងស្ថិតនៅភូមិ អង្គកែវ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រ ចាក់សំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ "ចាក់សំលៀកបំពាក់" ទៅតាមគំរូ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែង ដែលងាយមើលឃើញនៅមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្ដាល និងប្រធានក្រុមហ៊ុន អ៊ីស៊ីន ខេមបូឌា នីតធីង កូ អិលធីឌី ត្រូវអនុវត្តតាមប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃទីចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ស៊ុយ សែម

* * *

## ៣- នីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ៣០ ប្រក.វវស.ប្រ

### ស្តីពីការតែងតាំងមន្ត្រីរាជការ

### មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង

* * *

### រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ នៃ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់ឯកឧត្ដមអភិបាល ខេត្តស្វាយរៀង ឆ្នាំ ១៩៩៨

សំរេច

ប្រការ ១ : តែងតាំងលោក អ៊ុក គឹមនី ជាអនុប្រធានមន្ទីរ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួនត្រូវបានកែសំរួលតាមតួនាទីភារកិច្ចថ្មី ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង និងលោក អ៊ុក គឹមនី មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

រដ្ឋមន្ត្រី

ព្រះហស្ដលេខា និង ត្រា

នរោត្តម បុប្ផាទេវី

***

## ៨– ទីស្ដីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ១៥៧ ប្រក.កសក.ចត
### ស្ដីពីការបង្កើតការិយាល័យ
### វាយតំលៃហេតុប៉ះពាល់បរិស្ថាន

* * *

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ. ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ១៩៨៥ ស្ដីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

- បានឃើញ សេចក្តីសំរេចលេខ ១១៨១ ចត.កសក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋានផែនការ-ស្ថិតិ
- តាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**ប្រការ ១ :** បង្កើតការិយាល័យវាយតំលៃហេតុប៉ះពាល់បរិស្ថាន ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ-ស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ២ :** ការិយាល័យវាយតំលៃហេតុប៉ះពាល់បរិស្ថានមានភារកិច្ចដូចតទៅ ៖

- ជាសេនាធិការឲ្យនាយកដ្ឋានផែនការ-ស្ថិតិ លើការសិក្សារៀបចំគោលនយោបាយកម្មវិធី និងលើកវិធានការណែនាំអំពីការថែរក្សាការពារបរិស្ថាន សំរាប់ធនធានធម្មជាតិពាក់ព័ន្ធនឹងវិស័យកសិកម្ម ។
- ចូលរួមវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគ្រប់គំរោង ដោយសហការជាមួយអង្គភាពជំនាញ ហើយរាយការណ៍ និងស្នើវិធានការសំរេចពីក្រសួង ។
- ចូលរួមជាមួយក្រសួងបរិស្ថាន ដោះស្រាយរាល់ករណីដែលមានការប៉ះពាល់បរិស្ថាន ហើយដែលពាក់ព័ន្ធដល់វិស័យកសិកម្ម ។
- សហការជាមួយនាយកដ្ឋានបច្ចេកទេស សេដ្ឋកិច្ច និងផ្សព្វផ្សាយ ដើម្បីរៀបចំអត្ថបទណែនាំ អប់រំឲ្យប្រជាកសិករ យល់ដឹងអំពីហេតុប៉ះពាល់បរិស្ថាន ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ។

**ប្រការ ៣ :** ការិយាល័យវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានក្រសួង នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ឈាវ សុខ**

***